ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៤០ អយក.សណន

# សេចក្តីណែនាំ
## ស្តីពី
## ការបង្រៀន និងរៀនតាមបណ្តុំ សម្រាប់គ្រឹះស្ថានសិក្សាចំណេះទូទៅគ្រប់កម្រិត គ្រឹះស្ថានឧត្តមសិក្សា ទាំងសាធារណៈ និងឯកជន និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ

បន្ទាប់ពីការវាយតម្លៃលើដំណើរការបង្រៀននិងរៀនតាមបណ្តុះសម្រាប់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ក្នុងភូមិសាស្ត្រ ដែលមានហានិភ័យទាប ក្រសួងបានសង្កេតឃើញថា៖ ១)គ្រឹះស្ថានសិក្សាប្រមាណ ៣០ ភាគរយបានចាប់ដំណើរការតាមគ្រប់រូបភាព ស្របតាមសេចក្តីណែនាំ, ២)ការចូលរួមតាមគ្រប់រូបភាពពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ ដើម្បីធានាដំណើរការអប់រំប្រកបដោយសុវត្ថិភាព និងប្រុងប្រយ័ត្ន, ៣)ការបើកដំណើរការគ្រឹះស្ថានសិក្សាបានផ្តល់លទ្ធភាពឱ្យយើងអាចធ្វើតេស្ត និងរកឃើញអ្នកវិជ្ជមានកូវីដ-១៩ ទាំងលើបុគ្គលិកអប់រំ និងសិស្សានុសិស្សមួយចំនួនតូច ហើយបានចាត់ចែងព្យាបាលទាន់ពេលវេលា និងទប់ស្កាត់ កាត់ផ្តាច់ការឆ្លងរាលដាលបានល្អប្រសើរ, ៤)ករណីវិជ្ជមានកូវីដ-១៩ លើគ្រូបង្រៀន និងសិស្សានុសិស្ស ក្នុងរយៈពេល៧ថ្ងៃមុនបុណ្យភ្ជុំបិណ្ឌ និងរយៈពេល៧ថ្ងៃ ក្រោយថ្ងៃភ្ជុំបិណ្ឌ មានចំនួនតិចតួច និងអាចគ្រប់គ្រងបាន។ ម៉្យាងវិញទៀត មាតាបិតាអ្នកអាណាព្យាបាល គ្រូបង្រៀន និងសិស្សានុសិស្ស និស្សិតបានទទួលវ៉ាក់សាំងការពារកូវីដ-១៩ ក្នុងអត្រាខ្ពស់។

ឈរលើមូលដ្ឋាននេះ ដើម្បីឈានទៅដំណើរការអប់រំតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩ **ចាប់ពីថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០២១** ក្រសួងនឹងពង្រីកវិសាលភាពនៃការបង្រៀននិងរៀនតាមបណ្តុំសម្រាប់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន នៅគ្រប់កម្រិត ក្នុងភូមិសាស្ត្រទូទាំងរាជធានី ខេត្តទាំងអស់។ ការពង្រីកវិសាលភាពនេះ រួមបញ្ចូលទាំង ការពង្រីកពីកម្រិតថ្នាក់ទី៩ និងទី១២ រហូតដល់គ្រប់កម្រិតថ្នាក់នៅមធ្យមសិក្សា និងការពង្រីកវិសាលភាពដល់កម្រិតបឋមសិក្សា, គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន, វិទ្យាស្ថានជាតិអប់រំ, វិទ្យាស្ថានបច្ចេកវិទ្យា, គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ, គ្រឹះស្ថានសិក្សាអប់រំពិសេស, សាលាអនុវត្តន៍ និងវិទ្យាល័យចំណេះទូទៅនិងអប់រំបច្ចេកទេស ដោយគោរពតាមយ៉ាងខ្ជាប់ខ្ជួននូវបទដ្ឋានសុខាភិបាលជាធរមាន។

យោងតាមប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងសូមធ្វើការណែនាំនូវគោលការណ៍សំខាន់ៗស្តីពីការបង្រៀននិងរៀនតាមបណ្តុំនៅតាមគ្រឹះស្ថានសិក្សាគ្រប់កម្រិត នៅភូមិសាស្ត្រដែលហានិភ័យនៃជំងឺកូវីដ ១៩ អាចគ្រប់គ្រងបាន ដូចខាងក្រោម៖

**ទី១. ការបើកដំណើរការឡើងវិញគ្រឹះស្ថានសិក្សាចំណេះទូទៅ គ្រប់កម្រិតគ្រឹះស្ថានឧត្តមសិក្សា ទាំងសាធារណៈ និងឯកជន និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ នៅតាមក្រុង ស្រុក ខណ្ឌដែលជំងឺកូវីដ-១៩ អាចគ្រប់គ្រងបាន ដោយកំណត់រូបភាពនៃការបង្រៀននិងរៀនតាមបណ្តុំ ១៥ ទៅ ២០នាក់ និងឆ្លាស់វេន និងបន្តអនុវត្តនូវគម្លាតសុវត្ថិភាព និងវិធានការសុខាភិបាលចាំបាច់នានា**


អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

- គណៈអភិបាលរាជធានី ខេត្ត ត្រូវបន្តកំណត់ភូមិសាស្ត្រ ដើម្បីបើកដំណើរការគ្រឹះស្ថានសិក្សាគ្រប់កម្រិតឡើងវិញ
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវពិភាក្សាជាមួយគណៈអភិបាលរាជធានី ខេត្ត ដើម្បីបើកដំណើរការឡើងវិញសាលាមត្តេយ្យសិក្សា សាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ វិទ្យាល័យអប់រំពិសេស និងវិទ្យាល័យចំណេះទូទៅនិងអប់រំបច្ចេកទេស
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវរៀបចំយន្តការរៀននិងបង្រៀន និងត្រូវរៀបចំជាផែនការឱ្យបានច្បាស់លាស់ រួចផ្ញើមកក្រសួង ដើម្បីបូកសរុប
- គ្រប់គ្រឹះស្ថានឧត្តមសិក្សា និងវិទ្យាស្ថានបច្ចេកវិទ្យា ត្រូវស្នើសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា និងចុះអនុស្សារណៈនៃការយោគយល់គ្នា
- គ្រប់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងសាលាអនុវត្តន៍ ត្រូវស្នើសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងត្រូវយកចិត្តទុកដាក់ និងធានាសុវត្ថិភាពសុខភាពសិក្សាចំពោះគរុសិស្ស គរុនិស្សិត ដែលត្រូវត្រឡប់មកស្នាក់នៅក្នុងអន្តេវាសិកដ្ឋាន
- ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថានសិក្សាឡើងវិញក្នុងបរិបទនៃជំងឺកូវីដ-១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០។
- ត្រូវបង្កើតគណៈកម្មការសុខភាពសិក្សា ដោយមានការចូលរួមពីមាតាបិតា បុគ្គលិកសុខាភិបាល និងអាជ្ញាធរមូលដ្ឋាន ដើម្បីផ្តល់ព័ត៌មាន ត្រួតពិនិត្យ តាមដាន សុខភាពរបស់បុគ្គលិកអប់រំ និងអ្នកសិក្សាជាប្រចាំ
- *ត្រូវបន្តអនុវត្តកម្មវិធីសិក្សាបង្រួម ចំពោះគ្រឹះស្ថានសិក្សាចំណេះទូទៅ*
  - រៀបចំផែនការបង្រៀនប្រចាំសប្តាហ៍ និងប្រចាំខែឡើងវិញ ដោយផ្តោតលើខ្លឹមសារមេរៀនសំខាន់ៗ ដែលជាមូលដ្ឋានគ្រឹះក្នុងការបន្តការសិក្សានៅថ្នាក់បន្តបន្ទាប់ទៀត
  - សង្ខេបខ្លឹមសារមេរៀនដោយផ្តោតលើបញ្ញត្តិ ដែលធ្វើឱ្យសិស្សងាយយល់ និងអាចយកទៅអនុវត្តបាន
  - លើកទឹកចិត្តសិស្សដែលមានលទ្ធភាពរៀនតាមប្រព័ន្ធអេឡិចត្រូនិក ឱ្យចេះប្រើប្រាស់វីដេអូនៃការបង្រៀននិងសន្លឹកកិច្ចការ ដែលផលិតដោយនាយកដ្ឋានជំនាញនៃក្រសួង និងដែលមានចែកចាយក្នុងបណ្តាញតេឡេក្រាម វេបសាយ ឬកម្មវិធីទូរសព្ទដៃ
  - លើកទឹកចិត្តនិងជួយសិស្សឱ្យអនុវត្តលំហាត់ ឬធ្វើការហ្វឹកហាត់បន្ថែមនៅផ្ទះ
  - មុខវិជ្ជាផ្សេងទៀតត្រូវប្រឡងសិនដោយនឹងត្រូវរៀនបំពេញបន្ថែមនៅដើមឆ្នាំសិក្សាបន្ទាប់

**ទី២. ការបន្តបង្រៀន និងរៀនតាមបណ្តុំ ដែលមានចំនួនតិចជាង ១៥ ទៅ ២០នាក់ និងឆ្លាស់វេន ឬការរៀនតាមបែបចម្រុះ ចំពោះភូមិសាស្ត្រដែលមានហានិភ័យមធ្យមនិងខ្ពស់**

- ផ្តល់អាទិភាពទៅលើសិស្សថ្នាក់ទី៩ និងទី១២ និងពង្រីកវិសាលភាពដល់កម្រិតថ្នាក់ផ្សេងទៀតនៅមធ្យមសិក្សា និងបឋមសិក្សា ឱ្យរៀននៅតាមសាលារៀន ប៉ុន្តែក្នុងរូបភាពជាការរៀនតាមបណ្តុំ ដែលមានចំនួនតិចជាង ១៥ ទៅ២០នាក់ និងឆ្លាស់វេន ដើម្បីងាយស្រួលក្នុងការបង្រៀន និងការគ្រប់គ្រង

- ចំពោះកម្រិតថ្នាក់ផ្សេងទៀត អាចរៀបចំការរៀនជាបណ្តុំមិនឱ្យលើសពី១៥ ទៅ ២០នាក់ ទៅតាមស្ថានភាពជាក់ស្តែង ដោយអាចរៀបចំការរៀនតាមបណ្តុំនៅសាលារៀន និងបែងចែកវេន ឬបណ្តុំតាមចម្រុះថ្នាក់, ឬអាចរៀបចំបណ្តុំបន្ថែមនៅតាមផ្ទះ វត្តអារាម ឬកន្លែងសមស្រប
- រៀបចំចងក្រងបញ្ជីឈ្មោះសិស្សតាមបណ្តុំ និងតាមកម្រិតថ្នាក់នីមួយៗ។ ករណីបណ្តុំមានសិស្សតិចពេក អាចផ្តុំបកម្រិតថ្នាក់ចូលគ្នា ឬអាចផ្តុំបលើសពី ២កម្រិតថ្នាក់។ ចំពោះការធ្វើតេស្តសិស្សប្រចាំខែ ឬឆមាស ករណីគ្រូបង្រៀនថ្នាក់គួបតាមបណ្តុំមិនអាចរៀបចំខ្លឹមសារតេស្ត ឬកែកិច្ចការបាន ត្រូវសហការគ្នាជាមួយគ្រូបង្រៀននៃកម្រិតថ្នាក់នោះ
- បែងចែកគ្រូបង្រៀនឱ្យទទួលខុសត្រូវតាមបណ្តុំ ឬតាមកម្រិតថ្នាក់នីមួយៗ (ករណីគ្រូបង្រៀនមិនអាចសម្របសម្រួលបាន ត្រូវរៀបចំសិស្សធំនៅបណ្តុំជាមួយគ្នា ឬមាតាបិតាជួយសិស្សតូចៗ)
- *ត្រូវបន្តអនុវត្តវិធីសាស្ត្រនៃការសិក្សាតាមបែបចម្រុះ*
  - បន្តការរៀនតាមបែបចម្រុះដូចជា រៀនតាមអនឡាញ, ចែកឯកសារ, និងរៀនផ្ទាល់ក្នុងថ្នាក់ ដោយត្រូវបែកចែកតាមវេន តាមក្រុម និងត្រូវពង្រឹងអនាម័យជាប្រចាំ
  - លើកទឹកចិត្តសិស្សដែលមានលទ្ធភាពរៀនតាមប្រព័ន្ធអេឡិចត្រូនិក ឱ្យចេះប្រើប្រាស់វីដេអូនៃការបង្រៀន និងសន្លឹកកិច្ចការ ដែលផលិតដោយនាយកដ្ឋានជំនាញនៃក្រសួង និងដែលមានចែកចាយក្នុងបណ្តាញតេឡេក្រាម, វេបសាយ, ឬកម្មវិធីទូរសព្ទដៃ
  - បន្តអនុវត្តការបង្រៀនតាមបែបចម្រុះ និងតាមប្រព័ន្ធអេឡិចត្រូនិក ដោយគ្រូបង្រៀនអាចបង្រៀន Live និងផ្តល់ឱកាសដល់សិស្សក្នុងការធ្វើស្វ័យសិក្សា ដោយប្រើប្រាស់សៀវភៅសិក្សាគោល និងតាមបែបអេឡិចត្រូនិក
  - រៀបចំថ្នាក់ប៉ប៉នបន្ថែមសម្រាប់សិស្សថ្នាក់ទី៩ និងទី១២ ដើម្បីត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ
  - ជំរុញមាតាបិតាក្នុងការជួយលើកទឹកចិត្ត និងបង្កលក្ខណៈដល់ការសិក្សាពីចម្ងាយ និងស្វ័យសិក្សារបស់សិស្ស ជាពិសេសសិស្សតូចៗ។

**ទី៣- ការពង្រឹងវិធានការការពារសុខភាពបុគ្គលិកអប់រំ អ្នកសិក្សា ជាពិសេសគ្រូបង្រៀនដែលមានអាយុលើសពី ៥០ឆ្នាំឡើងទៅ និងការបង្ការទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ៖**

- គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាត្រូវបន្តពិនិត្យមើល, ចាត់វិធានការថែទាំ, លើកកម្ពស់អនាម័យ សណ្តាប់ធ្នាប់ និងសុវត្ថិភាពនៅតាមសាលារៀន
- មិនអនុញ្ញាតឱ្យមានការលក់ដូរចំណី ឬអាហារ និងសកម្មភាពហាត់កីឡា នៅក្នុងគ្រឹះស្ថានសិក្សានោះទេ
- គ្រូបង្រៀនដែលមានអាយុលើសពី៥០ឆ្នាំឡើងទៅ គួរតែបង្រៀនតាមអនឡាញ ឬចែកសន្លឹកកិច្ចការ។

- គ្រូបង្រៀនដែលមិនទាន់បានចាក់វ៉ាក់សាំងការពារកូវីដ-១៩ មិនទាន់អនុញ្ញាតឱ្យបង្រៀន នៅក្នុងសាលារៀនឡើយ និងត្រូវជំរុញ ឬលើកទឹកចិត្តឱ្យទៅទទួលវ៉ាក់សាំងការពារកូវីដ-១៩ នៅតាមទីតាំងដែលក្រសួងសុខាភិបាលបានកំណត់។ ករណីលើកលែង ចំពោះករណីដែលគ្រូពេទ្យមិនអនុញ្ញាតឱ្យចាក់វ៉ាក់សាំង គ្រូបង្រៀននៅតែអាចបង្រៀននៅក្នុងសាលារៀនបាន ប៉ុន្តែត្រូវមានវិធានការការពារ ឬប្រើប្រាស់ថ្នាំព្យាបាល ដើម្បីកុំឱ្យមានការចម្លង នៅក្នុងគ្រឹះស្ថានសិក្សា
- បណ្តុះបណ្តាលអំពីការអប់រំសុខភាពសិក្សា និងវិធានការការពារការឆ្លងជំងឺកូវីដ-១៩ ដល់បុគ្គលិកអប់រំនៅថ្នាក់ក្រោមជាតិ និងនៅតាមគ្រឹះស្ថានសិក្សា
- អំពាវនាវឱ្យមានការចូលរួម និងឧបត្ថម្ភពីសំណាក់មាតាបិតា និងគ្រប់អ្នកពាក់ព័ន្ធ ក្នុងការផ្គត់ផ្គង់ម៉ាសការពារ និងបរិក្ខារអនាម័យ នៅតាមគ្រឹះស្ថានសិក្សា។

**ទី៤- ការសម្រេចផ្អាក ឬ បើកដំណើរការថ្នាក់រៀនឡើងវិញក្នុងករណីមានការឆ្លងជំងឺនៅក្នុងគ្រឹះស្ថានសិក្សា**

- ករណី រកឃើញមានការឆ្លងនៅក្នុងក្រុមសិស្ស ឬថ្នាក់រៀន មន្ទីរអប់រំ យុវជន និងកីឡាត្រូវផ្អាកដំណើរការតែក្រុមសិស្ស ឬថ្នាក់រៀននោះប៉ុណ្ណោះ និងត្រូវចាត់ចែងយកអ្នកវិជ្ជមាន និងអ្នកដែលមានការ ពាក់ព័ន្ធទៅព្យាបាល និងធ្វើចត្តាឡីស័ក ១៤ ថ្ងៃ។ ដោយឡែក គ្រឹះស្ថានសិក្សាទាំងមូល ឬក្រុមសិស្ស ឬថ្នាក់រៀនដទៃទៀត នៅបន្តដំណើរការធម្មតា។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន លោកគ្រូ អ្នកគ្រូ អាជ្ញាធរដែនដី មាតាបិតា អ្នកអាណាព្យាបាលគ្រប់រូប សូមចូលរួមសហការអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ តុលា ឆ្នាំ ២០២១
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- រដ្ឋបាលរាជធានី ខេត្ត
- អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
  **"ដើម្បីជ្រាបជាព័ត៌មាន"**
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- សមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា
  **"ដើម្បីអនុវត្ត"**
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានរដ្ឋបាល